# ហេតុអ្វីជំរឿនមានសារៈសំខាន់ចំពោះ
# យុវជនអាមេរិកដើមកំណើតអាស៊ីអាគ្នេយ៍

ជារៀងរាល់10ឆ្នាំម្តង រដ្ឋាភិបាលសហរដ្ឋអាមេរិកតម្រូវឱ្យមានការរាប់ចំនួន **មនុស្សគ្រប់រូប** ដែលរស់នៅក្នុងសហរដ្ឋអាមេរិកតាមរយៈការស្ទង់មតិមួយដែលគេហៅថា "ជំរឿនប្រជាជន"។ ជំរឿនប្រជាជនឆ្នាំក្រោយនឹងចាប់ផ្តើមនៅខែមីនាឆ្នាំ2020 ហើយវានឹងកំណត់ថាតើថវិការដ្ឋាភិបាលសហព័ន្ធចំនួន 800 ពាន់លានដុល្លារនឹងត្រូវបែងចែកទៅដល់សហគមន៍ទូទាំងប្រទេសយ៉ាងដូចម្តេច។ ប្រជាជនអាមេរិកដើមកំណើតអាស៊ីអាគ្នេយ៍ដែលជាយុវជនមានចំនួនច្រើនគួរសមះ

- អាយុជាមធ្យមរបស់ប្រជាជនអាមេរិកដើមកំណើតអាស៊ីអាគ្នេយ៍គឺទាបជាងអាយុប្រជាជនអាមេរិកទូទៅដែលមានអាយុជាមធ្យមគឺ37.2ឆ្នាំ។ ក្នុងចំណោមប្រជាជនអាមេរិកដើមកំណើតអាស៊ីអាគ្នេយ៍ ជនជាតិអាមេរិកដើមកំណើតម៉ុងគឺមានអាយុជាមធ្យមទាបជាងគេបង្អស់គឺមានអាយុជាមធ្យមត្រឹមតែ20.5[1]ឆ្នាំ ។
- ជនជាតិអាមេរិកដើមកំណើតម៉ុង មានចំនួនយុវជនដែលស្ថិតនៅក្នុងអាយុរៀននៅមហាវិទ្យាល័យច្រើនជាងគេ (អាយុចន្លោះពី18-24ឆ្នាំ) បើប្រៀបធៀបទៅនឹងយុវជនគ្រប់ជាតិសាសន៍ទាំងអស់ និងជាតិសាសន៍អាស៊ីអាគ្នេយ៍ផ្សេងទៀត។
- ជនជាតិអាមេរិកដើមកំណើតឡាវនិងខ្មែរ ក៏មានចំនួនយុវជនដែលស្ថិតនៅក្នុងអាយុរៀននៅមហាវិទ្យាល័យខ្ពស់ជាងយុវជនទូទៅផងដែរដែលមានចំនួន 12% សំរាប់យុវជនឡាវ និង 14%សំរាប់យុវជនខ្មែរ។[2]

## តើលោកអ្នកដឹងទេ?

ជនជាតិអាមេរិកដើមកំណើតម៉ុងជាង **40%** មានអាយុក្រោម **18** ឆ្នាំ គឺជាអាត្រាខ្ពស់បំផុតបើប្រៀបធៀបទៅនឹងយុវជនគ្រប់ជាតិសាសន៍ទាំងអស់ ក៏ដូចជាយុវជនអាមេរិកដើមកំណើតអាស៊ីអាគ្នេយ៍ផ្សេងទៀត។ អាត្រាយុវជនអាមេរិកដើមកំណើតម៉ុងគឺមានចំនួនទ្វេដងនៃយុវជនអាមេរិកស្បែកស។[3]

[1] U.S. Census Bureau, 2010 SF2, Table DP-1.
[2] U.S. Census Bureau, 2010 Census SF2, Table PCT3.
[3] U.S. Census Bureau, 2010 SF2, Table DP-1.




## សំណួរដែលមានគេសួរច្រើន

## ហេតុអ្វីបានជាយុវជនគួរយកចិត្តទុកដាក់ចំពោះជំរឿន?

ការរាប់ចំនួនប្រជាជនតាមរយៈជំរឿនគឺជួយកំណត់ថាតើធនធានឬថវិការប៉ុន្មាននឹងបែងចែកទៅដល់សាលារៀន សេវាថែទាំសុខភាព និងកម្មវិធីសំខាន់ៗផ្សេងទៀត នេះមានន័យថា កាលណាមានមនុស្សកាន់តែច្រើននៅក្នុងសហគមន៍របស់លោកអ្នកចូលរួមក្នុងជំរឿន នោះសហគមន៍របស់លោកអ្នកក៏នឹងទទួលបានធនធានថវិការច្រើនទៅតាមនោះដែរ។ នៅពេលដែលលោកអ្នកចូលរួមបំពេញជំរឿនប្រជាជន លោកអ្នកបានចូលរួមចំណែកក្នុងការធានាអោយបានថាក្រុមគ្រួសារនិងសហគមន៍របស់លោកអ្នកទទួលបានចំណែកថវិកា សេវាកម្មនិងអ្នកតំណាងនយោបាយដោយស្មើភាពគ្នា! ទិន្នន័យដែលបានមកពីជំរឿននឹងត្រូវបានយកទៅប្រើប្រាស់តាមគ្រប់មធ្យោបាយរួមមាន៖

### វិស័យអប់រំ៖

ការចូលរួមក្នុងជំរឿនមានន័យថាជួយអោយមានថវិកាបន្ថែមសម្រាប់ជួយកម្មវិធីអប់រំសំខាន់ៗដែលផ្ដល់អត្ថប្រយោជន៍ដល់ខ្លួនលោកអ្នកផ្ទាល់ ដែលក្នុងនោះរួមមានជួយដល់សិស្សនិស្សិតដែលខ្វះខាត កម្មវិធីសិក្សាជាពីរភាសា និងការអប់រំថ្នាក់អាជីពនិងថ្នាក់បច្ចេកទេសផ្សេងៗ។

### ការបែងចែកធនធានដោយស្មើភាពគ្នា៖

ទិន្នន័យដែលបានមកពីជំរឿនជួយកំណត់អំពីរបៀបបែងចែកថវិកាសហព័ន្ធទៅដល់កម្មវិធីនិងសេវាកម្មផ្សេងៗ។ ហើយអ្នកជំនួញក៏ប្រើប្រាស់ទិន្នន័យដែលបានមកពីជំរឿនដើម្បីធ្វើការសម្រេចចិត្តទៅលើទីតាំងដែលត្រូវចុះធ្វើវិនិយោគទុន និងបង្កើតការងារផងដែរ។ ការបំពេញជំរឿននឹងជួយធានាអោយបានថាលោកអ្នកក៏ដូចជាក្រុមគ្រួសារនិងសហគមន៍របស់លោកអ្នកអាចទទួលបានចំណែកធនធានទាំងនោះដោយស្មើភាពគ្នា។

### អោយគេមើលឃើញនិងស្គាល់៖

ការបំពេញជំរឿនជួយផ្ដល់ជាព័ត៌មានដែលមានតំលៃជាច្រើនទៅដល់អ្នកដែលមានសិទ្ធក្នុងការសម្រេចចិត្តថាតើត្រូវបែងចែកធនធាននៅកន្លែងណា និងជួយឱ្យពួកគេស្គាល់ពីសហគមន៍និងយល់ដឹងពីតម្រូវការរបស់យើង ក៏ដូចជាការចូលរួមចំណែកដ៏មានតម្លៃរបស់ពួកយើងដល់ប្រទេសជាតិ។ អ្នកតស៊ូមតិក៏នឹងទទួលបានទិន្នន័យដើម្បីព្រាងនិងជំរុញគោលនយោបាយនានាដើម្បីជួយអោយការរស់នៅក្នុងសហគមន៍របស់លោកអ្នកបានប្រសើរឡើង។

**តំណាងផ្នែកនយោបាយ៖** លទ្ធផលជំរឿនជួយកំណត់តំណាងផ្នែកនយោបាយ ដោយកំនត់នូវចំនួនអាសនៈនៅក្នុងរដ្ឋសភាដែលរដ្ឋនីមួយៗទទួលបាន និងថាតើព្រំប្រទល់សង្កាត់សម្រាប់ជ្រើសរើសរដ្ឋាភិបាលថ្នាក់រដ្ឋនិងថ្នាក់មូលដ្ឋានត្រូវកំនត់គូសយ៉ាងដូចម្តេច។ នេះគឺជាការសបញ្ជាក់អោយឃើញអំពីអំណាចផ្នែកនយោបាយដែលសហគមន៍របស់លោកអ្នកមាន!




## តើអាស័យដ្ឋានមួយណាដែលខ្ញុំគួរតែប្រើសំរាប់បំពេញជំរឿនប្រសិនបើខ្ញុំនៅស្នាក់នៅក្នុងសាលា និងមិនរស់នៅក្នុងផ្ទះ?

បើយោងតាមច្បាប់ជំរឿន លោកអ្នកគួរតែបំពេញជំរឿនដោយប្រើអាស័យដ្ឋានដែលលោកអ្នកស្នាក់នៅភាគច្រើន ឬ អាស័យដ្ឋានណាដែលលោកអ្នកស្នាក់នៅនៅថ់ថ្ងៃដែលគេធ្វើជំរឿន (គឺនៅថ្ងៃទី**1** ខែមេសាឆ្នាំ **2020**) ។ ឧទាហរណ៍ ប្រសិនបើលោកអ្នកកំពុងតែស្នាក់នៅអន្តេវាសិកដ្ឋានរបស់សាលា នៅថ់ថ្ងៃជំរឿនប្រជាជន នោះគឺជាអាស័យដ្ឋានដែលលោកអ្នកគួរតែសសេរចូលក្នុងប្រដាសជំរឿន។

## តើខ្ញុំរាប់បញ្ចូលមិត្តភក្តិស្នាក់នៅរួមបន្ទប់ជាមួយខ្ញុំនៅក្នុងជំរឿនដែរឬទេ?

នៅពេលលោកអ្នកបំពេញជំរឿន លោកអ្នករាប់បញ្ចូលមនុស្សទាំងអស់ដែលរស់នៅជាមួយលោកអ្នកនៅក្នុងថ្ងៃដែលគេធ្វើជំរឿនប្រជាជន ដោយរួមទាំងមិត្តភក្តិស្នាក់នៅរួមបន្ទប់ជាមួយលោកអ្នកផងដែរ!

## តើកំរងសំណួរជំរឿនមានជម្រើសអោយរើសភេទផ្សេងៗទៀតដែរឬទេ?

កំរងសំណួរជំរឿនមានតែភេទពីរអោយរើសទេ។ នាពេលកន្លងមក មានអ្នកដែលបានរំលងមិនឆ្លើយសំណួរនេះ ប៉ុន្តែពួកគេនៅតែត្រូវបានគេរាប់បញ្ចូលនៅក្នុងជំរឿន។

## តើខ្ញុំត្រូវចូលរួមក្នុងជំរឿនបានយ៉ាងដូចម្តេចប្រសិនបើខ្ញុំកំពុងសិក្សានៅក្រៅប្រទេស ឬធ្វើដំណើរចុះឡើងក្នុងរយៈពេលប្រាំមួយខែខាងមុខនេះ?

លោកអ្នកអាចចូលរួមក្នុងជំរឿនបានតាមរយៈការបំពេញជំរឿនតាមប្រព័ន្ធអ៊ីនធឺណេត! ចាប់ពីពាក់កណ្តាលខែមីនាឆ្នាំ**2020** រហូតដល់ដើមខែឧសភាឆ្នាំ**2020** ការិយាល័យជំរឿននឹងផ្ញើអោយលោកអ្នកតាមប៉ុស្តិ៍សំបុត្រនូវកំរងសំណួរជំរឿននិងព័ត៌មានអំពីរបៀបបំពេញជំរឿនតាមប្រព័ន្ធអ៊ីនធឺណេត រួមទាំងលេខសំគាល់សំងាត់របស់លោកអ្នកផងដែរ។

## តើខ្ញុំត្រូវប្រើអាស័យដ្ឋានបច្ចុប្បន្នមួយណានៅក្នុងជំរឿនប្រសិនបើខ្ញុំត្រូវធ្វើដំណើរចុះឡើងក្នុងរយៈពេលប្រាំមួយខែខាងមុខនេះ?

លោកអ្នកគួរតែប្រើអាស័យដ្ឋានណាដែលលោកអ្នករស់នៅនិងដេកនៅច្រើនបំផុត
បើទោះបីជាលោកអ្នកនឹងមិនត្រលប់ទៅនៅទីកន្លែងនោះក្នុងរយៈពេលជាច្រើនខែក៏ដោយ។

## តើលេខកូដសំគាល់សំងាត់របស់ខ្ញុំសំរាប់បំពេញជំរឿនតាមប្រព័ន្ធអ៊ិនធឺណេត គឺជាអ្វីដែរ?

ប្រសិនបើលោកអ្នកមិនប្រាកដអំពីលេខកូដសំគាល់សំងាត់របស់លោកអ្នកសំរាប់បំពេញជំរឿនតាមប្រព័ន្ធអ៊ិនធឺណេត
អ្នកនៅតែអាចបំពេញជំរឿនរបស់លោកអ្នកបានតាមរយៈគេហទំព័ររបស់ការិយាល័យជំរឿន
ដោយលោកអ្នកគ្រាន់តែផ្តល់ជាអាស័យដ្ឋានរបស់លោកអ្នក។

## តើមានជំនួយអ្វីខ្លះសំរាប់អ្នកដែលមិនចេះអាន សរសេរ ឬនិយាយភាសាអង់គ្លេសបានល្អ?

ប័ណ្ណជំរឿនដែលបំពេញតាមប្រព័ន្ធអ៊ិនធឺណែត និងប្រព័ន្ធទូរស័ព្ទសំរាប់ជួយក្នុងការបំពេញជំរឿនមាន
ផ្តល់ជូនជា**12** ភាសាខុសៗគ្នា ដែលរួមមានទាំងភាសាវៀតណាមផងដែរ។
ការិយាល័យជំរឿនក៏មានផ្តល់ជា
សទ្ទានុក្រមជាភាសាផ្សេងៗ  កាតសំរាប់សំគាល់ភាសានានា
និងសៀវភៅមគ្គុទេសភាសាដែលមានភាសាចំនួន**59**ខុសៗគ្នា ដែលរួមមានទាំង ភាសាម៉ុង ភាសាខ្មែរ ភាសាឡាវ និងភាសាវៀតណាម។

## **សូមចូលរួមអនុវត្តសកម្មភាពខាងក្រោម៖**

ត្រូវដឹងថា ចូលរួមក្នុងការរាប់ចំនួនប្រជាជនគឺមានឥទ្ធិពល! សូមចុះឈ្មោះធ្វើជាទូតជំរឿនឆ្នាំ2020
និងជួយធានាអោយបានថាបងប្អូនជនជាតិអាមេរិកដើមកំណើតអាស៊ីអាគ្នេយ៍យើងទាំងអស់
ត្រូវបានគេស្គាល់និងដឹងលឺ។ សូមស្វែងយល់បន្ថែមតាមរយៈ៖ bit.ly/SEARACCensusPledge ។

## **តើលោកអ្នកអាចធ្វើអ្វីខ្លះដើម្បីធានាអោយបានថាលោកអ្នកត្រូវបានគេរាប់បញ្ចូលក្នុងជំរឿន?**

1. បំពេញក្រដាសជំរឿនរបស់លោកអ្នក។ ហើយជួយប្រាប់ដល់មិត្តភក្តិនិងក្រុមគ្រួសាររបស់លោកអ្នកអំពីជំរឿនប្រជាជន និងជួយពន្យល់ពួកគាត់អំពីសារៈសំខាន់នៃការចូលរួមក្នុងជំរឿន។
2. ឆែកមើលឯកសារព័ត៌មានខាងក្រោមនេះ resource(s) page  ដើម្បីអោយដឹងថា នៅពេលណាដែលក្រដាសជំរឿននឹងធ្លាក់មក របៀបបំពេញក្រដាសជំរឿន មានផ្តល់ជូនជាភាសាអ្វីខ្លះ ក៏ដូចជាព័ត៌មានជាច្រើនទៀតផងដែរ។
3. ដាក់ពាក្យចូលធ្វើការឱ្យការិយាល័យជំរឿន ជាមន្ត្រីចុះធ្វើជំរឿន ដែលជាអ្នកចុះទៅដល់ផ្ទះរបស់ប្រជាជនដើម្បីរាប់ពួកគាត់ប្រសិនបើពួកគាត់មិនបានបំពេញជំរឿន។ សូមស្វែងរកព័ត៌មានបន្ថែមនៅទីនេះ here!

សូមថ្លែងអំណរគុណដល់ដៃគូសហការរបស់យើង ដែលមានដូចជាអង្គការ Boat People SOS-Houston, The Cambodian Family of Santa Ana, Freedom Inc., the Fresno Center, និងអង្គការ Iu-Mien Community Services ដែលបានជួយបកប្រែឯកសារទាំងនេះ។
ឯកសារផ្តល់ជូនព័ត៌មានពិតទាំងអស់នេះអាចទាញយកបានជាទំរង់ឯកសារWord
និងអាចកែតំរូវទៅតាមតំរូវការរបស់សហគមន៍ផ្សេងៗ។ សម្រាប់សំណួរបន្ថែម
សូមទាក់ទងតាមរយៈអ៊ីមែលsearac@searac.org